# សន្សំថវិកា និងថាមពល នៅរដូវក្តៅនេះ

## ការការពារពីពន្លឺព្រះអាទិត្យ

- សូមបិទវាំងននន និងបន្ទះបិទបង្អួចនៅពេលថ្ងៃ ជាពិសេសសម្រាប់បង្អួចដែលបើកទៅទិសខាងត្បូង។
- អាចដំឡើងស្រទាប់ហ្វីល( Film)លើកញ្ចក់បង្អួច ដើម្បីកាត់បន្ថយការផ្ទេរកម្តៅពីខាងក្រៅ និងបង្កើនប្រសិទ្ធភាពប្រើប្រាស់ថាមពល។

## ស្វែងយល់អំពី Mass Save®

- ស្នើសុំការវាយតម្លៃថាមពលផ្ទះពី Mass Save® ដើម្បីស្វែងរកការកែលម្អការប្រើប្រាស់ថាមពលក្នុងផ្ទះ ដែលមិនគិតថ្លៃ ឬមានតម្លៃទាប។
- បិទចន្លោះ និងបន្ថែមសម្ភារៈបាំងកំដៅក្នុងផ្ទះ ដើម្បីរក្សាខ្យល់ត្រជាក់នៅខាងក្នុង និងបង្កើនភាពងាយស្រួលក្នុងការរស់នៅ។
- ស្វែងរកប្រាក់ជំនួយ ដើម្បីធ្វើឲ្យប្រសើរឡើង(Upgrade)នូវឧបករណ៍កម្តៅ និងត្រជាក់ ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល និងបន្ថយវិក្កយបត្រ។
- ពិចារណាប្រើម៉ាស៊ីនបូមកំដៅ។ ម៉ាស៊ីនបូមកំដៅអាចត្រជាក់ខ្យល់ក្នុងផ្ទះបានយ៉ាងមានប្រសិទ្ធភាពនៅថ្ងៃក្តៅ និងផ្តល់កម្តៅនៅថ្ងៃត្រជាក់។ អ្នកអាចកំណត់ពេលពិគ្រោះយោបល់អំពីការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូន ដើម្បីទទួលបានការគាំទ្រដោយផ្ទាល់សម្រាប់គម្រោងរបស់អ្នក។
- ទទួលបានប្រាក់ជំនួយសម្រាប់ឧបករណ៍កំណត់សីតុណ្ហភាពឆ្លាតវៃ ឬអាចកំណត់កម្មវិធីបាន ដែលមានលក្ខណៈសម្បត្តិសមរម្យ។

## កាត់បន្ថយការប្រើប្រាស់ថាមពល

- សូមបិទ ឬ ដកឧបករណ៍អេឡិចត្រូនិកចេញពីភ្លើង នៅពេលមិនប្រើប្រាស់។
- ជៀសវាងការប្រើប្រាស់ឧបករណ៍ធំៗ ដូចជា ម៉ាស៊ីនលាងចាន និងម៉ាស៊ីនបោកខោអាវ នៅពេលដែលតម្រូវការប្រើប្រាស់ថាមពលខ្ពស់ (ម៉ោង 3–9 ល្ងាច នៅថ្ងៃដែលមានអាកាសធាតុក្តៅ)។ វាជួយកាត់បន្ថយការប្រើប្រាស់ប្រភពថាមពលដែលមានថ្លៃខ្ពស់ និងបង្កការបំពុល ហើយជួយកាត់បន្ថយតម្រូវការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអគ្គិសនីថ្មី ដែលត្រូវបានចំណាយពីវិក្កយបត្រអគ្គិសនី។

## ប្រើកង្ហារ

- កង្ហារបង្កើតខ្យល់បក់ ដែលអាចធ្វើឲ្យអ្នកមានអារម្មណ៍ត្រជាក់ចុះប្រហែល 7–10°F។
- កង្ហារពិដានជួយបង្វិលខ្យល់។ សូមដំណើរការកង្ហារតាមទិសបញ្ច្រាសទ្រនិចនាឡិកា ដើម្បីបង្ខំឲ្យខ្យល់ត្រជាក់ចុះក្រោម។
- សូមបិទកង្ហារនៅពេលចាកចេញពីបន្ទប់។ កង្ហារជួយបន្ថយកំដៅសម្រាប់មនុស្ស មិនមែនសម្រាប់បន្ទប់ទេ។
- ប្រើកង្ហារជាមួយម៉ាស៊ីនត្រជាក់ ដើម្បីអាចកំណត់សីតុណ្ហភាពម៉ាស៊ីនត្រជាក់ឲ្យខ្ពស់ឡើងបន្តិច។

## ប្រើម៉ាស៊ីនត្រជាក់ឲ្យមានប្រសិទ្ធភាព

- សូមបិទបង្អួចទាំងអស់ មុនពេលបើកម៉ាស៊ីនត្រជាក់។
- កំណត់សីតុណ្ហភាពនៅចន្លោះ 74–78°F។
- បន្ថែមសីតុណ្ហភាព នៅពេលដេក ឬនៅក្រៅផ្ទះ។ ការកំណត់សីតុណ្ហភាពឲ្យខ្ពស់ឡើង 5–7°F រយៈពេល 8 ម៉ោង អាចជួយកាត់បន្ថយវិក្កយបត្រអគ្គិសនីបានរហូតដល់ប្រហែល 10% ក្នុងមួយឆ្នាំ។
- ដំឡើងហើយមិនចាំបាច់ព្រួយបារម្ភទៀត៖ ប្រើឧបករណ៍កំណត់សីតុណ្ហភាពដែលអាចកំណត់កម្មវិធី ឬឆ្លាតវៃ ដើម្បីកែតម្រូវសីតុណ្ហភាពដោយស្វ័យប្រវត្តិ។
- សូមបិទទ្វារនៅបន្ទប់ដែលមានម៉ាស៊ីនត្រជាក់ប្រភេទដាក់បង្អួច ដើម្បីកាត់បន្ថយបរិមាណខ្យល់ដែលត្រូវត្រជាក់។
- សូមបិទម៉ាស៊ីនត្រជាក់ប្រភេទដាក់បង្អួច នៅពេលចាកចេញពីបន្ទប់។
- នៅពេលយប់មានសីតុណ្ហភាពត្រជាក់ សូមបិទម៉ាស៊ីនត្រជាក់ និងបើកបង្អួច ដើម្បីអោយខ្យល់ចូលតាម ធម្មជាតិ។.

**ស្កេនកូដ QR ដើម្បីទទួលបានគន្លឹះសន្សំថាមពលបន្ថែម៖**

គេហទំព័រ Mass.Gov

Massachusetts Clean Energy Center